Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 2/2 (April 2001): 50–54



# God and Money
## Part Two—Debt and Savings

*Neal YOUNGQUIST*

We all struggle at times with decisions about money and possessions. Should we buy or not buy? How can I improve my standard of living? Should I leave the comforts of my job for one with a larger salary though I may not be as happy? Should I go into debt to buy a new motorbike or a house? How can I better manage my money and possessions?

These questions and others often weigh on our hearts and minds. Some people are aware of them more than others, yet our response to these thoughts impacts our daily lives. So how should we manage our money and possessions for the glory of God? After all, God has entrusted them—whether little or much—to us as stewards.[1]

This article attempts to provide some guidance in the practical day-to-day matters of correctly managing money. "God and Money, Part One"[2] addressed our attitudes about money, specifically greed and contentment, as well as teaching on the blessedness of giving. With this as a foundation, Part Two will focus on the contrasting issues of debt and savings.

### Debt—Financial Slavery

Proverbs 22:7 states, *the borrower is servant to the lender.* Debt usually demands the borrower to pay back to the lender within a period of time both the principal (the amount borrowed) and an additional payment for interest (a fee for the use of the money borrowed). If the loan conditions are not met, the borrower is

[1] 1 Chron 29:14.
[2] Robert Choy, *Honeycomb* vol. 1, no. 2 (October 2000): 47–67.

placed in an increasingly difficult financial situation that can lead to loss of possessions, family, reputation, and well-being.



Realizing the entangling consequences of borrowing, Paul encouraged the Roman church to keep *out of debt and owe no man anything except to love one another.*[3] With this in mind, what should the Christian's attitude be toward debt? In many cultures, borrowing money is an acceptable practice for funding education, purchasing land, a house, a motorbike, or a car. Businesses routinely borrow capital to fund the expansion of operations. So why was Paul so fixed in teaching the church to stay away from debt? Because of the dangers associated in becoming enticed by the attractiveness of "easy money." Remember, it is easy to receive money but often quite difficult to pay it back.

Before entering into debt one should consider the following questions:



- *Am I borrowing funds for something I need or something that I want?* Placing oneself into debt for nonessential purchases is often a dangerous trap that can lead to dire consequences. Borrowing for investment in an income-producing activity may be appropriate, provided a feasible business plan and strong commitment exists to pay off the loan.
- *Am I committed to paying off the debt as soon as possible?* Good money management principles strongly encourage obtaining financial freedom from debt entanglements as soon as possible. Do not allow yourself to remain in bondage for a long period of time.
- *Are the terms reasonable?* Carefully review the interest rate and payment terms before signing a loan contract. Is the interest rate competitive within the marketplace? Are the terms

---

[3]Rom 13:8.

generally easy to comply with? Can your monthly income support the payment schedule?

- *Can the purchase be postponed until sufficient funds are saved?* Our normal feelings often lead us to act quickly, but waiting has sure rewards. Patience and discipline—especially concerning material possessions—are godly attributes that each of us needs to build within our lives.
- *Am I prepared to deal with the effects of debt on myself and my family?* The stress of financial obligations can have numerous effects such as marriage discord, loss of sleep, worry, and health problems. In addition, the pressure to pay financial burdens can lead one into ruinous temptations such as stealing, cheating, bribery, etc.
- *Do I have the peace of God?* If God's leading is not present do not proceed, rather wait on Him for guidance. The almighty Jehovah God who created the heavens and earth may have other methods to meet your needs. He wants us to trust in Him not in earthly financial resources that will eventually pass away.[4]

In summary, the sound advice is to keep our financial obligations to a minimum. If borrowing is a necessity, understand the consequences and commit to releasing yourself from the weight of debt as quickly as possible. Above all else our desire should be to keep ourselves as free as possible to follow, serve, and obey God according to His will for us.[5] With this as our goal, an anchor of debt is the last thing we need.



## Savings—Preparing for the Future

Savings is an often overlooked financial principle. But its importance should not be disregarded. As demonstrated in the

[4] 1 John 2:15–17.
[5] 2 Tim 2:4.

following illustrations, savings can be the difference between life and death.



The Bible notes several examples of saving present resources for future use in time of need. One such example is from God's insect world. The common ant is well spoken of in Proverbs 30:24–25 as exceedingly wise because it gathers and stores food during the warm season for use during the cool season when resources are not as plentiful.[6] We can learn much from nature if only we will stop and reflect on God's wondrous creation.

Another demonstration of savings wisdom comes from the life of Joseph in Genesis 41. God revealed to Joseph the details of Pharaoh's dream and its interpretation that foretold seven years of plenty followed by seven years of famine. In response to this prediction of abundance and need, Joseph wisely recommended to Pharaoh a savings plan to adequately prepare for the future. Twenty percent of the crops during the years of plenty were to be saved for use during the years of famine. This storehouse proved to be invaluable as it provided both for Egypt's needs as well as those of the surrounding region—including Joseph's family living in Canaan.

These two examples clearly show the wisdom of savings. As a resource, savings can serve as a bridge to meet insufficiencies during difficult times or for sudden needs that occur without warning. Yet in everything there needs to be a balance. Prosperity can turn our affections away from God and onto our storehouse of riches.

In the parable of the rich fool Jesus warned about the dangers of trusting in wealth.[7] The rich fool relied on his earthly riches stored in corruptible barns rather than trusting in God and his

---

[6]Prov 6:6–8.

[7]Luke 12:13–21.



eternal riches. His life was suddenly snatched away without the opportunity to enjoy the fruits of his labor. By keeping riches solely for himself and not sharing it with others in need, the rich fool lost all he had. Saving is a wise practice as long as we continue to maintain our affections on God. Remember Jesus' insight into the lives of human creation—*where your treasure is, there your heart will be also.*[8]



One of the main challenges of practicing saving in Cambodia is the lack of reliable savings vehicles. Several commercial banks in Cambodia offer savings services but require large amounts beyond the ability of most individuals—US$100 or more—to open or maintain an account. Yet this should not be a reason to discourage savings, but rather serve as a goal to save towards. It is never too late to start a habit of regular savings. No matter how small the amount—even one, two, or five hundred riel every day or week—regular savings will amount to much over several years.

Saving at work is another potential option. In an effort to encourage savings, some employers will deduct a portion of wages to set aside in a savings plan for employees. If such a plan is not available at your workplace, perhaps one can be established. Other creative ideas are possible, including group savings with trusted friends or co-workers.

One key to good financial health is a personal savings program. Whether at home, the workplace, or through a reliable commercial bank, a disciplined savings program yields results. Most important, it is a valuable lifeline during times of emergencies or distress. We do not know for certain what the future holds, but at least we can do our best to prepare for it.

---

[8]Luke 12:34.

សំណុំឆីកឃ្មុំ ២/២ (មេសា ២០០១)៖ ៥៥-៦៣



នៀល យ៉ាំងគ្វីស

# ព្រះ និង ប្រាក់

## *ភាគទី២:ការជាប់បំណុល និង ការសន្សំ*

យើងទាំងអស់គ្នា មានការលំបាកគ្រប់ពេលក្នុងការសម្រេចចិត្ត លើផ្នែកលុយកាក់ និង ទ្រព្យសម្បត្តិ ។ តើយើងគួរទិញ ឬ មិនគួរទិញ? តើខ្ញុំអាចធ្វើឲ្យស្ថានភាពរស់នៅរបស់ខ្ញុំ បានប្រសើរឡើង ដោយរបៀបណា? តើគួរឲ្យខ្ញុំចាកចេញពីកន្លែងធ្វើការ ដែលមានការកក់ក្តៅទៅធ្វើការនៅកន្លែងថ្មីមួយទៀត ដែលបានប្រាក់ខែច្រើន ទោះបីជាខ្ញុំមិនសប្បាយក៏ដោយឬ? តើខ្ញុំត្រូវជំពាក់បំណុលគេ ដើម្បីទិញម៉ូតូថ្មី ឬ ផ្ទះថ្មីឬ? តើខ្ញុំអាចចាត់ចែងទុកដាក់មើលថែទាំប្រាក់កាស និង ទ្រព្យសម្បត្តិរបស់ខ្ញុំឲ្យបានប្រសើរឡើង ដោយរបៀបណា?

សំណួរទាំងនេះ និង សំណួរជាច្រើនទៀតកំពុងសង្កត់ធ្ងន់ ក្នុងចិត្ត និង គំនិតរបស់យើង ។ មនុស្សខ្លះដឹងពីបញ្ហានេះច្រើនជាងអ្នកដទៃ ទោះជាយ៉ាងណាក៏ដោយ ការឆ្លើយតបរបស់យើងចំពោះគំនិតទាំងនេះ មានឥទ្ធិពលលើជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ។ ដូច្នេះតើយើងគួរចាត់ចែងលុយកាក់ និង ទ្រព្យសម្បត្តិរបស់យើង ដើម្បីថ្វាយសិរីល្អថ្វាយដល់ព្រះជាម្ចាស់ដោយរបៀបណា? ជាពិសេសជាងនេះទៅទៀតនោះ គឺព្រះ

ជាម្ចាស់បានផ្តល់ឲ្យយើងនូវសម្បត្តិទាំងនោះ ទោះបីតិច ឬ ច្រើនក្តី នោះយើងត្រូវចេះមើលថែទាំឲ្យបានល្អ ។[១]

ខ្ញុំសរសេរនេះ ដើម្បីព្យាយាមនាំផ្លូវលោកអ្នកឲ្យចេះចាត់ចែងលុយកាក់យ៉ាងត្រឹមត្រូវល្អ ក្នុងការរស់នៅប្រចាំថ្ងៃរបស់លោកអ្នក ។ "ព្រះ និង ប្រាក់ភាគទី១"[២] បានលើកឡើងពីឥរិយាបថរបស់យើងចំពោះលុយកាក់ ជាពិសេសទាក់ទងលើការលោភលន់ និង ការស្កប់ចិត្ត ព្រមទាំងលើកឡើងមកនិយាយអំពីសេចក្តីបង្រៀន អំពីការទទួលព្រះពរ ដោយសារការថ្វាយតង្វាយដល់ព្រះជាម្ចាស់ផងដែរ ។ ដោយមានមូលដ្ឋានគ្រឹះនេះរួចហើយ ព្រះ និង ប្រាក់ ភាគទីពីរផ្តោតនូវការយកចិត្តទុកដាក់លើសាច់រឿងផ្ទុយពីនោះ គឺការជាប់បំណុល និង ការសន្សំប្រាក់ ។

## ការជាប់បំណុល គឺជាទាសភាពផ្នែកហិរញ្ញវត្ថុ

សុភាសិត ២២:៧ បានចែងថា កូនបំណុលជាទាសកររបស់ម្ចាស់ប្រាក់ ។ បំណុលតាមធម្មតាទាមទារ ឲ្យអ្នកជំពាក់សងមកម្ចាស់បំណុលក្នុងរយៈពេលមួយ គឺសងទាំងការទាំងដើម ។ បើសិនជាមានលក្ខណ្ឌនៃការខ្ចីប្រាក់នោះ មិនបានស្របតាមការព្រមព្រៀងគ្នានោះទេ កូនបំណុលត្រូវទទួលរងនូវការលំបាក ផ្នែកហិរញ្ញវត្ថុកាន់តែខ្លាំងឡើង ដែលជាហេតុបណ្តាលឲ្យមាន ការបាត់បង់ដល់ទ្រព្យសម្បត្តិ គ្រួសារ កេរ្តិ៍ឈ្មោះ និង សុខមាលភាព ។

ដោយស្គាល់នូវផលវិបាកផ្សេងនៃការជំពាក់ប្រាក់គេលោក ប៉ូលបានលើកទឹកចិត្តក្រុមជំនុំនៅក្រុងរ៉ូម មិនឲ្យជំពាក់អ្វីនរណាក្រៅពីជំពាក់សេច

---

[១] ១ របាក្សត្រ ២៩:១៤ ។

[២] Robert Choy, *Honeycomb* vol. 1, no. 2 (October 2000): 47–67.



ក្តីស្រឡាញ់ទៅវិញទៅមកនោះឡើយ ។ [៣]ដោយមានគំនិតនេះជាប់នៅជាមួយ តើគ្រីស្តបរិស័ទគួរមានឥរិយាបថបែបណា ចំពោះការជាប់បំណុលនោះ? នៅក្នុងទំនៀមទម្លាប់វប្បធម៌ជាច្រើនការខ្ចីលុយគឺជាទម្លាប់មួយ ដែលគេអាចទទួលយកបានចំពោះការខ្ចីលុយសម្រាប់យកទៅរៀនសូត្រ(បង់ថ្លៃសិក្សាអប់រំ) ទិញដីធ្លី ទិញផ្ទះ ទិញម៉ូតូ ឬ ក៏ទិញឡាន ។ ក្នុងមុខជំនួញគេតែងខ្ចីប្រាក់ ដើម្បីមកពង្រីករបររកស៊ី ។ ដូច្នេះ ហេតុអ្វីបានជាលោកប៉ូលបង្រៀនដល់ក្រុមជំនុំ ឲ្យជៀសឲ្យផុតពីការជាប់ជំពាក់បំណុលគេ? ពីព្រោះគ្រោះថ្នាក់ ដែលទាក់ទងក្នុងការខ្ចីលុយនោះ ធ្វើឲ្យមនុស្សជក់ចិត្តនឹងគំនិត "បានទទួលលុយយ៉ាងងាយ" ។ ចូរចងចាំថា ការខ្ចីលុយបានយ៉ាងងាយកន្លងមក លុះដល់ពេលសងវិញពិបាកខ្លាំងណាស់ ។ មុននឹងខ្ចីលុយគេនោះ អ្នកគួរគិតពិចារណានូវសំណួរដូចតទៅនេះគឺ៖



- **តើខ្ញុំខ្ចីលុយនេះ មកទិញអ្វីមួយដែលខ្ញុំត្រូវការ ឬអ្វីមួយដែលខ្ញុំចង់បាន?** ការបណ្តោយខ្លួនឲ្យជាប់បំណុល ដោយសារតែយកមកទិញរបស់ ដែលមិនសំខាន់ចាំបាច់នោះ គឺជារឿយៗ ជាអន្ទាក់មួយ ដែលប្រកបដោយគ្រោះថ្នាក់ ដែលនាំឲ្យមានផលវិបាកដ៏ធ្ងន់ធ្ងរបំផុត ។ ការខ្ចីលុយមក ដើម្បីធ្វើការបណ្តាក់ទុនរកស៊ី ប្រហែលជាអាចសមរម្យបានបើអ្នកមានផែនការច្បាស់លាស់ និង មានការប្តូរផ្តាច់ក្នុងការទូទាត់សងយ៉ាងច្បាស់លាស់នោះ ។

---

(៣) *រ៉ូម ១៣:៨ ។*

- **តើខ្ញុំអាចប្តូរផ្តាច់សងបំណុល ឲ្យបានឆាប់តាមដែលធ្វើបានឬទេ?** គោលការណ៍ នៃការចាត់ចែងលុយកាក់ល្អត្រឹមត្រូវគឺជំរុញលើកទឹកចិត្តយ៉ាងមុតមាំក្នុងការដោះខ្លួនឲ្យរួចពីការជាប់ជំពាក់បំណុលនោះកាន់តែឆាប់កាន់តែល្អ ។ ចូរកុំឲ្យខ្លួនអ្នកជាប់ចំណាំងរបៀបនេះយូរពេក ។
- **តើរយៈពេលខ្ចីនោះសមហេតុសមផលឬទេ?** ចូរពិនិត្យឡើងវិញ ឲ្យបានល្អិតល្អន់នូវអត្រាការប្រាក់ និង រយៈពេលដែលត្រូវសងមុនពេលចុះហត្ថលេខា លើកិច្ចសន្យាកុងត្រាខ្ចីប្រាក់នោះ ។ តើអត្រាការប្រាក់នោះមានការប្រជែងគ្នានៅក្នុងទីផ្សារឬទេ? តើអណត្តិនៃការខ្ចីប្រាក់នោះជាទូទៅងាយស្រួលឲ្យអ្នកធ្វើតាមឬទេ? តើចំណូលប្រចាំខែរបស់អ្នកអាចចេញសងថ្លៃជំពាក់នោះស្របតាមពេលកំណត់ឬទេ?
- **តើការទិញនេះអាចផ្អាកសិន រហូតដល់សន្សំលុយគ្រប់សិនបានឬទេ?** អារម្មណ៍ជាទូទៅរបស់យើង តែងតែទាញឲ្យយើងធ្វើអ្វីលឿន ភ្លាមៗ ប៉ុន្តែការរង់ចាំនោះ ប្រាកដជាមានរង្វាន់ល្អជាក់ជាមិនខាន ។ ការអត់ធ្មត់ និង ដាក់កម្រិតខ្លួនឯង ជាពិសេសទាក់ទងទៅនឹងការទិញសម្ភារៈ ធ្វើជាទ្រព្យសម្បត្តិ ការអត់ទ្រាំនេះឯង ជាលក្ខណៈនៃនិស្ស័យ ដែលល្អប្រពៃ ដែលយើងប្រុសស្រី ត្រូវបង្កើតឲ្យមាននៅក្នុងជីវិតរស់នៅរបស់យើង ។
- **តើខ្ញុំប្រុងប្រៀប ដើម្បីដោះស្រាយជាមួយឥទ្ធិពលប៉ះពាល់ដល់ខ្លួនខ្ញុំផ្ទាល់ និង គ្រួសាររបស់ខ្ញុំហើយឬនៅ?** ភាពតានតឹង នៃកាតព្វកិច្ច ផ្នែកហិរញ្ញវត្ថុអាចមានឥទ្ធិពលយ៉ាងច្រើន ដូចជាការមិនចុះសំរុងគ្នា នៅក្នុងគ្រួសារ ដេកមិនលក់ ព្រួយចិត្ត និងមានបញ្ហាសុខភាព ។ លើសពីនេះទៅទៀតសម្ពាធធ្ងន់ ដែលកើតឡើងពីបន្ទុកធ្ងន់ផ្នែកថវិកា អាចនាំឲ្យធ្លាក់ទៅក្នុងសេចក្តីល្បួងជាច្រើន ដូចជាការលួចកិបកេង បន្លំស៊ីសំណូក ជាដើម ។ល។

- **តើខ្ញុំមានសេចក្ដីសុខសាន្ត របស់ព្រះជាម្ចាស់ឬទេ?** បើសិនជាការដឹកនាំរបស់ព្រះជាម្ចាស់មិនមានទេ នោះចូរកុំទាន់ធ្វើ ជាការប្រសើរគួររង់ចាំឲ្យព្រះអង្គនាំផ្លូវវិញ ។ ព្រះអម្ចាស់យេហូវ៉ា ជាព្រះដែលប្រកបដោយឫទ្ធិចេស្ដា ដែលបានបង្កើតផ្ទៃមេឃនិងផែនដី ព្រះអង្គអាចមានវិធីសាស្ត្រផ្សេងពីនេះ ដើម្បីផ្គត់ផ្គង់ដល់សេចក្ដីត្រូវការរបស់អ្នក ។ ព្រះអង្គចង់ឲ្យយើងទុកចិត្តដល់ព្រះអង្គ មិនត្រូវឲ្យយើងទុកចិត្ត និង ធនធានហិរញ្ញវត្ថុនៅលើផែនដីនេះឡើយ ដែលនឹងត្រូវរលាយបាត់ ទៅនៅថ្ងៃណាមួយនោះ[៤] ។

និយាយឲ្យខ្លី ខ្ញុំសូមផ្ដល់យោបល់ដ៏ត្រឹមត្រូវមួយដល់អ្នកថា បើចាំបាច់ត្រូវខ្ចីប្រាក់គេ សូមកុំខ្ចីច្រើនពេកក្រែងលោសងគេវិញមិនរួច ។ បើសិនការខ្ចីនោះវាចាំបាច់នោះ ចូរឲ្យយល់ពីផលវិបាក និង ការប្ដូរផ្ដាច់ក្នុងការទូទាត់សងបំណុលនោះវិញឲ្យបានឆាប់ តាមដែលអាចធ្វើបាន ។ ហើយលើសពីនេះទៅទៀត បំណងចិត្តរបស់យើងត្រូវតែខំដោះខ្លួនយើងឲ្យរួចពីការជាប់ជំពាក់ ដែលជាបន្ទុកនៅក្នុងចិត្ត ប្រយោជន៍ឲ្យយើងអាចដើរតាមបំរើ និងស្ដាប់បង្គាប់ ដល់ព្រះស្របតាមបំណងព្រះហឫទ័យរបស់ព្រះអង្គសម្រាប់យើងរាល់គ្នា[៥] ។ នេះជាគោលដៅរបស់យើង ជាបង្គោលយុថ្កានៃបំណុល គឺជាកិច្ចការចុងក្រោយ ដែលយើងត្រូវការ ។



---

(៤) ១ យ៉ូហាន ២:១៥-១៧ ។

(៥) ២ ធីម៉ូថេ ២:៤ ។

## ការសន្សំ គឺជាការត្រៀមទុកបំរុងសំរាប់ថ្ងៃអនាគត

ការសន្សំជារឿយៗ តែងតែត្រូវមើលរំលងនៃគោលការណ៍ផ្នែកហិរញ្ញវត្ថុ ។ ប៉ុន្តែភាពសំខាន់របស់ការសន្សំនេះ មិនត្រូវខ្ជីខ្ជាឡើយ ។ ដូចដែលបានបង្ហាញនៅក្នុងការគូសបញ្ជាក់ដូចខាងក្រោមនេះ ការសន្សំអាចបង្ហាញឲ្យឃើញពីភាពប្លែកគ្នា រវាងជីវិត និង សេចក្តីស្លាប់ ។

ព្រះគម្ពីរបានចែងពីគំរូ ជាច្រើននៃការសន្សំធនធាន ពេលបច្ចុប្បន្ន



សម្រាប់ប្រើនៅថ្ងៃអនាគត ក្នុងពេលដែលខ្វះខាត ។ គំរូបែបនេះ យើងឃើញនៅក្នុងសត្វល្អិត មួយប្រភេទដែលព្រះបង្កើតមក ។ សត្វស្រមោច ដូចមានចែងយ៉ាងច្បាស់នៅក្នុង សុភាសិត ៣០:២៤-២៥ គឺជាសត្វដែលវៃឆ្លាតបំផុត ពីព្រោះវាប្រមូលអាហារស្តុកទុកនៅរដូវក្តៅ ដើម្បីត្រៀមទុកប្រើនៅរដូវវស្សា នៅពេលធនធានខ្សត់ខ្សោយ មិនសូវសម្បូណ៌[៦] ។ យើងអាចរៀនបានច្រើនពីធម្មជាតិ បើសិនជាយើងគ្រាន់តែឈប់មួយភ្លែត ហើយនិងសញ្ជឹងគិតពីស្នាព្រះហស្តដ៏ល្អអស្ចារ្យរបស់ព្រះជាម្ចាស់ ។

ការបង្ហាញមួយផ្សេងទៀត ឲ្យឃើញប្រាជ្ញាក្នុងការការសន្សំបានមកពីគំរូនៃជីវិតរស់នៅរបស់យ៉ូសែប នៅក្នុងលោកុប្បត្តិ(កំណើតពិភពលោក) ៤១ ។ ព្រះជាម្ចាស់បានបង្ហាញឲ្យយ៉ូសែបនូវការកាត់ស្រាយសប្តិ

---

[៦] *សុភាសិត ៦:៦-៨ ។*

ដ៏ពិស្តារ របស់ស្តេចផារ៉ោន និង ការបកស្រាយនោះបានប្រាប់ឲ្យបានដឹង មុនពីរយៈពេល៧ ឆ្នាំ ជាឆ្នាំសម្បូណ៌ហើយនិង៧ ឆ្នាំក្រោយមកគឺជាឆ្នាំនៃគ្រោះទុរភិក្ស ។ នៅក្នុងការឆ្លើយតបទៅនឹងទំនាយនៃភាពសម្បូណ៌ភោគផល និងភាពខ្វះខាតនេះ យ៉ូសែបបានទូលថ្វាយនូវការផ្តល់គំនិតដ៏វៃឆ្លាតដល់ស្តេចផារ៉ោន នូវគម្រោងការសន្សំឲ្យបានគ្រប់គ្រាន់ល្មមសម្រាប់ប្រើនៅថ្ងៃអនាគត ។ ២០%នៃភោគផលនៅក្នុងឆ្នាំ ដែលសម្បូណ៌ត្រូវសន្សំទុក ដើម្បីប្រើនៅក្នុងឆ្នាំដែលខ្វះខាតស្បៀង ។ ជង្រុកស្តុកទុកស្បៀងអាហារ បានបង្ហាញឲ្យឃើញថាមានស្បៀងអាចផ្គត់ផ្គង់នូវសេចក្តីត្រូវការរបស់ប្រទេសអេស៊ីព ព្រមទាំងប្រទេសជិតខាងនៅក្នុងតំបន់នោះផងដែរ គឺរួមទាំងគ្រួសាររបស់យ៉ូសែប ដែលរស់នៅឯស្រុកកាណានផង ។

គំរូទាំងពីរនេះ បង្ហាញយ៉ាងច្បាស់នូវប្រាជ្ញានៃការសន្សំ ។ ការសន្សំទុកគឺជាធនធានមួយ ដែលអាចជួយចម្លងនូវភាពខ្វះខាត នៅក្នុងអំឡុងពេលដ៏លំបាក ឬ សម្រាប់ប្រើដោះស្រាយនូវសេចក្តីត្រូវការ ជាបន្ទាន់មួយ ដែលកើតឡើង ដោយមិនបានឲ្យដឹងជាមុន ។ តែទោះបីជាយ៉ាងណាក៏ដោយ គ្រប់យ៉ាងទាំងអស់ត្រូវមានតុល្យភាព ។ ភាពសម្បូណ៌សប្បាយអាចប្រែក្លាយឲ្យយើងឃ្លាតឆ្ងាយពីព្រះជាម្ចាស់ និង នាំឲ្យយើងបែរទៅរក ការយកចិត្តទុកដាក់លើឃ្លាំងមត៌ក ដែលជាទ្រព្យសម្បត្តិរបស់យើងនោះ ។



នៅក្នុងរឿងប្រៀបប្រដូច ពីអ្នកមានដ៏ល្បីល្បើម្នាក់ ដែលព្រះយេស៊ូបានព្រមានចំពោះគ្រោះថ្នាក់នៃការទុកចិត្តដល់ទ្រព្យសម្បត្តិ[៧] ។ អ្នកមានដ៏ល្បីល្បើម្នាក់ទុកចិត្ត លើទ្រព្យសម្បត្តិ

---

[៧] លូកា ១២:១៣-២១ ។

ដែលកណ្ដៀរកោរកណ្ដុរកាត់បាននោះ តែមិនបានទុកចិត្តដល់ព្រះជាម្ចាស់ និង ទ្រព្យសម្បត្តិដ៏អស់កល្បជានិច្ចរបស់ព្រះអង្គនោះឡើយ ។ ជីវិតរបស់គាត់ស្រាប់តែត្រូវឆក់យកទៅបាត់មួយរំពេច ដោយគ្មានឱកាសនឹងសប្បាយរីករាយនូវអ្វីដែលជាផលផ្លែនៃការ ខំប្រឹងប្រែងរបស់គាត់នោះឡើយ ។ ដោយសារតែគាត់ខំសន្សំទុកសំរាប់តែខ្លួនមិនដែលចេះបែងចែករំលែកដល់អ្នកដទៃ ដែលកំពុងក្រក្រីឡើយ អ្នកមានម្នាក់នោះត្រូវបាត់បង់គ្មានសល់អ្វីបន្តិចសោះឡើយ ។ ការសន្សំ គឺជាទម្លាប់មួយដ៏មានប្រាជ្ញា ដរាបណាយើងនៅតែបន្តស្រឡាញ់ព្រះជាម្ចាស់ ។ ចូរនឹកចាំពីសេចក្ដីបំផុសនៅក្នុងគំនិតរបស់ព្រះយេស៊ូ ដែលព្រះអង្គបានបញ្ជាក់ពីជីវិតរស់នៅរបស់មនុស្ស គឺថាសម្បត្តិទ្រព្យរបស់ឯងនៅឯណា នោះចិត្តឯងនៅឯណោះដែរ[៨] ។



បញ្ហាសំខាន់មួយ នៅក្នុងការសន្សំប្រាក់នៅក្នុងប្រទេសកម្ពុជានោះ គឺខ្វះប្រព័ន្ធសន្សំប្រាក់ ដែលជាទីគួរឲ្យទុកចិត្តបាន ។ ធនាគារពាណិជ្ជកម្មភាគច្រើន នៅក្នុងប្រទេសកម្ពុជា បានផ្ដល់សេវាកម្មសន្សំប្រាក់ ប៉ុន្តែតម្រូវឲ្យតម្កល់ទុកពី ១០០ ដុល្លា ឬ លើសពីនេះទៅទៀត ដើម្បីអាចបើកគណនីសន្សំ ឬ អាចរក្សាគណនីសន្សំនោះបាន ។ តែទោះជាយ៉ាងណាក៏ដោយការនេះ មិនមែន ជាហេតុផល ដែលបង្អាក់ដំណើរការមិនឲ្យយើងសន្សំប្រាក់នោះឡើយ ។ ប៉ុន្តែត្រូវរក្សាពីគោលដៅ ដែលយើងត្រូវសន្សំកុំឲ្យភ្លេចឡើយ ។ បើអ្នកចង់ចាប់ផ្ដើមទម្លាប់នៃការសន្សំប្រាក់នោះ វាមិនទាន់យឺតពេលនៅឡើយទេ ។ មិនថាឡើយចំនួននោះតិចតួចប៉ុណ្ណានោះឡើយ ។ ទោះបីមួយរយ ពីររយ

[៨] *លូកា ១២:៣៤ ។*

ឬប្រាំរយរៀល ជារៀងរាល់ថ្ងៃ ឬ ជារៀងរាល់សប្តាហ៍ គឺថាការសន្សំយ៉ាងទៀងទាត់នឹងអាចកើនឡើងច្រើន អស់រយៈពេលយូរឆ្នាំទៅ ។

ការសន្សំលុយនៅកន្លែងធ្វើការ គឺជាជំរើសមួយដ៏ប្រពៃអស្ចារ្យ ។ នៅក្នុងកិច្ចខំប្រឹងប្រែង ដើម្បីជំរុញឲ្យមានការសន្សំប្រាក់ និយោជកខ្លះនឹងកាត់ប្រាក់ខែមួយចំនួន ដើម្បីសន្សំទុកឲ្យនិយោជិក ។ បើនៅក្នុងកន្លែងធ្វើការរបស់អ្នក មិនមានប្រព័ន្ធសន្សំបែបនោះទេ ប្រហែលជាគេអាចបង្កើតប្រព័ន្ធនោះឡើងបាន ។ គំនិតច្នៃប្រឌិតផ្សេងទៀតអាចធ្វើបាន រួមទាំងការរួមគ្នាសន្សំជាក្រុម ជាមួយមិត្តភក្តិ ដែលទុកចិត្តបាន ឬជាមួយអ្នកធ្វើការជាមួយគ្នា ។

គន្លឹះដ៏ល្អ ក្នុងការសន្សំប្រាក់ដ៏ប្រសើរនោះ គឺកម្មវិធីសន្សំប្រាក់ផ្ទាល់ខ្លួន ។ ទោះបីជានៅផ្ទះក្តី នៅកន្លែងធ្វើការ ឬ ផ្ញើនៅធនាគារ ដែលអាចទុកចិត្តបាន កម្មវិធីសន្សំប្រាក់ ដែលមានច្បាប់គ្រប់គ្រងល្អ នាំឲ្យហុចលទ្ធផលល្អប្រសើរ ។ សំខាន់បំផុតនោះ គឺមានតម្លៃដ៏យូរលង់ ក្នុងពេលត្រូវការជាបន្ទាន់ ឬ ពេលមានវិបត្តិ ។ យើងមិនដឹងថាថ្ងៃអនាគតនោះ នឹងទៅជាយ៉ាងណា ប៉ុន្តែយ៉ាងហោចណាស់យើងអាចខំប្រឹងឲ្យអស់ពីសមត្ថភាពរបស់យើង ដើម្បីត្រៀមសម្រាប់ការនោះ ។